# ស្ទឹងជីនិត

## គម្រោងធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទស្ទឹងជីនិត

GRET
Professionnels du développement solidaire

CEDAC

KINGDOM OF CAMBODIA
MINISTRY OF WATER RESOURCES AND METEOROLOGY

## បទពិសោធន៍សំខាន់ៗ ពីការអនុវត្តគម្រោង

# បទពិសោធន៍សំខាន់ៗ
# ពីការអនុវត្តគម្រោង

Philippe Rousseau & Sébastien Balmisse
កែសម្រួលដោយ : Patricia Toelen, Jean-Philippe Fontenelle, Christian Castellanet

ខែកុម្ភៈ ឆ្នាំ២០០៩

១- ទស្សនវិស័យប្រវត្តិសាស្រ្តអំពីគម្រោង
២- ការគ្រោងប្លង់ហេដ្ឋារចនាសម្ព័ន្ធ និងការពិចារណាសម្រាប់ការសាងសង់
៣- ការគាំទ្រដល់ការបង្កើត និងការពង្រឹង ស.ក.ប.ទ
៤- ការគ្រប់គ្រងគម្រោង និងការពិចារណាសម្រាប់ការបង្កើតស្ថាប័ន
៥- សេចក្តីសន្និដ្ឋាន

# ១~ ទស្សនវិស័យប្រវត្តិសាស្ត្រអំពីគម្រោង

## ១.១- វិសាលភាពបឋមនៃគម្រោង




ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) បានផ្តោតកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនគួរឱ្យកត់សម្គាល់ទៅលើ អាទិភាពមួយក្នុងចំណោមអាទិភាពចំបង៧របស់រាជរដ្ឋាភិបាល កម្ពុជា (RGC): ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដើម្បីបង្កើន ផលិតកម្មកសិកម្ម ។

នៅក្នុងឆ្នាំ១៩៩៧ ការសិក្សាបឋមមួយបានពិចារណាទៅលើលទ្ធភាពនៃការស្តារឡើងវិញនូវ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដែលបង្កើតឡើងនៅក្រោមរបបប៉ុលពតនៅតំបន់ស្ទឹងជីនិត ។ ដោយសារតែអសន្តិសុខនៅក្នុងតំបន់គម្រោង ការសិក្សាលទ្ធភាពបឋមនេះត្រូវបានធ្វើឡើងមិនបានស៊ីជម្រៅឡើយ ហើយលទ្ធផលនៃការសិក្សានេះបានបង្ហាញនូវកង្វះទិន្នន័យចំបាច់ដែលអាចជឿជាក់បានដូចជា ឋានលេខា ដី និងជលវិទ្យា ។

នៅក្នុងឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំដល់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងទីភ្នាក់ងារអភិវឌ្ឍន៍ បារាំង (AFD) ឱ្យគាំទ្រដល់ការស្តារឡើងវិញនូវ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នេះ ។ ការស្ទង់មតិបន្ថែមអំពី សេដ្ឋកិច្ច-សង្គមត្រូវបានធ្វើឡើងតាមសំណើរបស់ AFD ដែលបញ្ជាក់ថា កសិករ និងអាជ្ញាធរមូលដ្ឋានមានការជំរុញ លើកទឹកចិត្ត និងត្រៀមខ្លួនជាស្រេចដើម្បីរៀបចំខ្លួនឯងក្នុងការគ្រប់គ្រងទឹក ។ ចំពោះបញ្ហាបច្ចេកទេសដែលទាក់ទងនឹងការស្តារហេដ្ឋារចនាសម្ព័ន្ធ ពុំមានសំណើឱ្យមានការស្ទង់មតិបន្ថែមណាមួយឡើយ ហើយវិសាលភាពបឋមនៃគម្រោងត្រូវបានកំណត់ដែលមានដូចជា ការស្តារប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក និង ប្រព័ន្ធផ្លូវចេញចូល (ផ្លូវជនបទ) ។ គោលបំណង គឺដើម្បីផ្តល់ការស្រោចស្រពបន្ថែមដល់ផ្ទៃដីគោលដៅ ៧.០០០ហិកតា ក្នុងអំឡុងពេលរដូវវស្សា ដែល ៣០% នៃផ្ទៃដីនេះអាចទទួលបានការស្រោចស្រពគ្រប់គ្រាន់នៅក្នុងអំឡុងពេលរដូវប្រាំង ។

គម្រោងធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទស្ទឹងជីនិត (SCIRIP) ត្រូវបានអនុវត្តចាប់តាំងពីខែកញ្ញា ឆ្នាំ២០០១ រហូតដល់ខែកក្កដា ឆ្នាំ២០០៨ ដោយមានកិច្ចព្រមព្រៀងផ្តល់មូលនិធិរួមគ្នារវាង ADB (១៦លានដុល្លារសហរដ្ឋអាមេរិក លើការសិក្សាគ្រោងប្លង់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ) និង AFD (សម្រាប់ការពង្រឹង ស្ថាប័ន ស.ក.ប.ទ) និងរាជរដ្ឋាភិបាលកម្ពុជា ។ សមាសភាពសំខាន់៧នៃគម្រោងត្រូវបានកំណត់ដូចខាងក្រោម :

១- ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកដើម្បីគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រ រួមទាំងប្រព័ន្ធដោះទឹក និង ការកែលម្អវិធីសាស្ត្រធ្វើស្រែចម្ការ (ដែលអនុវត្តដោយ MOWRAM ជាមួយនឹងការផ្តល់មូលនិធិពី AFD) ។

២- ការស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹក (ដែលអនុវត្តដោយ MOWRAM ជាមួយនឹងការផ្តល់មូលនិធិពី ADB) ។

៣. ការអភិវឌ្ឍផ្លូវចេញចូល និងទីផ្សារជនបទ (ដែលអនុវត្តដោយ MRD ជាមួយនឹងការផ្តល់មូលនិធិពី ADB) ។

# ១. ទស្សនវិស័យប្រវត្តិសាស្ត្រអំពីគម្រោង

## ១.២- បរិបទសង្គម និងអេកូឡូស៊ី-កសិកម្មរបស់គម្រោងស្ទឹងជីនិត




គម្រោងនេះមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រចន្លោះ តំបន់ទំនាបវាលស្រែក្រោម និងតំបន់វាលស្រែនៅជួរ កណ្តាល *(ស្រែកណ្តាល)*។ តំបន់ស្ទឹងជីនិតត្រូវបានកំណត់ចរិកលក្ខណៈជាប្រពៃណីដោយការអនុវត្តកសិកម្មដែលមានទិសដៅគ្រប់គ្រងជំនន់ពី ទន្លេពីរដែលនៅជាប់តំបន់គម្រោង : ទន្លេស្ទឹងជីនិត និងទន្លេតាំងក្រសាំង ។

កសិករនៅក្នុងតំបន់នេះ កំពុងប្រើប្រាស់បណ្តាញប្រឡាយ/ចង្អូរទឹក ដើម្បីពង្រីក និងគ្រប់គ្រងទឹកជំនន់សម្រាប់ស្រោចស្រពស្រូវរដូវវស្សាជាលក្ខណៈប្រពៃណី។ ផែនការធារាសាស្ត្រដ៏ធំមួយ ដែលបង្កើតឡើងនៅក្រោមរបបខ្មែរក្រហមត្រូវបានប្រើប្រាស់ដើម្បីស្រោចស្រពលើផ្ទៃដីស្រែ ១២.០០០ ទៅ ១៥.០០០ ហិកតា ដែលស្ថិតនៅជុំវិញទន្លេ ទាំងពីរនេះ ។

ស្របពេលជាមួយគ្នានេះដែរ ទម្លាប់ធ្វើស្រែចម្ការជាលក្ខណៈប្រពៃណីដែលរួមមាន ការផ្សារភ្ជាប់គ្នាដ៏ស្មុគស្មាញនូវប្រព័ន្ធដាំដុះខុសៗគ្នា។ ការពិត កសិករកំពុងបង្កើនសកម្មភាពដាំដុះតាមបែបកសិកម្មយថាផលក្នុងកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយហានិភ័យឱ្យមកនៅត្រឹមកម្រិតអប្បបរមា ។ ប្រតិទិនដាំដុះដំណាំ ត្រូវបានរៀបចំផ្អែកលើសកម្មភាព ជាច្រើនដូចជាការធ្វើស្រូវឡើងទឹក និងស្រូវតាមវាលទំនាបពឹងផ្អែកលើទឹកភ្លៀង ការចិញ្ចឹមសត្វពាហនៈ និងការនេសាទ ការប្រមូលអនុផលព្រៃឈើ។ សារសំខាន់នៃសកម្មភាពនីមួយៗក្នុងចំណោមសកម្មភាពទាំងនេះនៅក្នុងចំណូលរបស់ កសិករទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងទីតាំងនៃដីស្រែរបស់កសិករ។ ដូច្នេះ លំដាប់ទីតាំងដីស្រែបានចាប់កំណើតឡើងចេញ ពីការបែងចែកដីធ្លីឡើងវិញនៅក្រោយការដួលរលំនៃរបបខ្មែរក្រហមនៅក្នុងឃុំចំនួនបី ដែលមានព្រំប្រទល់ជាប់គ្នា ។ ការបែងចែកដីធ្លីឡើងវិញនេះបណ្តាលឱ្យមានទម្លាប់ដាំដុះផ្សេងៗគ្នានៅក្នុងតំបន់គម្រោង SCIRIP និងការរំពឹងចង់បានខុសៗគ្នាពីសំណាក់កសិករទាក់ទិនទៅនឹងការអភិវឌ្ឍបណ្តាញធារាសាស្ត្រ ។

# ១. ទស្សនវិស័យប្រវត្តិសាស្ត្រអំពីគម្រោង

## ១.៣- ដំណាក់កាលដំបូងនៃការអនុវត្តគម្រោង




ដំណាក់កាលដំបូងនៃការអនុវត្តគម្រោង SCIRIP ផ្តោតទៅលើការគ្រោងប្លង់លម្អិត និងការពិគ្រោះយោបល់ជាបឋមជាមួយកសិករ ។ ដំណាក់កាលនេះបង្ហាញឱ្យឃើញថា ក្នុងករណីភាគច្រើនបំផុត ស្ថានភាពនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តមានសភាពចាស់ទ្រុឌទ្រោមពេកដែលមិនអាចធ្វើការជួសជុលឡើងវិញបាន ។ លទ្ធផលនៃដំណាក់កាលនេះ ក៏បានបង្ហាញផងដែរថា ថ្លៃចំណាយសម្រាប់ការស្តារឡើងវិញត្រូវបានប៉ាន់ស្មានទាបជ្រុល ។ ដូច្នេះ ទីប្រឹក្សាសំខាន់ៗដែលទទួលបន្ទុកក្នុងការគ្រោងប្លង់បានស្នើឡើងនូវជម្រើសផ្សេងៗទៅ ADB និង MOWRAM កាលពីខែកក្កដា ឆ្នាំ២០០៣ ។ សេចក្តីសម្រេចត្រូវបានធ្វើឡើង ដើម្បីពិនិត្យឡើងវិញទៅលើវិសាលភាពនៃគម្រោង : គម្រោង SCIRIP នឹងអនុញ្ញាតឱ្យមានទឹកសម្រាប់ការស្រោចស្រពទៅលើផ្ទៃដីស្រែតែ ៣.០០០ ហិកតា នៃផ្ទៃដីស្រែទាំង ៧.០០០ ហិកតា ដែលត្រូវបានគ្រោងជាដំបូង ក្នុងអំឡុងពេលរដូវវស្សា និងទៅលើផ្ទៃដី ១.៨០០ ហិកតា ក្នុងអំឡុងពេលរដូវប្រាំង ។

គំរូបច្ចេកទេសក៏មានការផ្លាស់ប្តូរខ្លាំងខ្លាផងដែរ : គម្រោងនេះនឹងមិនស្តារហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នោះទេ ប៉ុន្តែបែបនឹងប្រើប្រាស់នូវគ្រោងប្លង់នៃប្រព័ន្ធប្រឡាយ និងប្រព័ន្ធដោះទឹកដ៏ស្អេកស្កះមួយ ។ បណ្តាញចែកចាយទឹកនេះ នឹងអនុញ្ញាតដល់ការផ្តល់ទឹកក្នុងបរិមាណថេរនៅកម្រិតក្បាលដីស្រែតាមរយៈកាលវិភាគចែកចាយទឹកនៅកម្រិតប្រឡាយរងទី ៣ ។ ចាប់ពីពេលដំបូងមក ហេតុផលចម្បងរបស់ទីប្រឹក្សាទទួលបន្ទុកគ្រោងប្លង់គឺ "ការបញ្ចុះបញ្ចូលគំនិតនេះ" ដល់អតិថិជន និងម្ចាស់ជំនួយគឺថា គំរូបច្ចេកទេសនេះបានបង្ហាញថា វាមានផលល្អជាងនេះក្នុងការកាត់បន្ថយការងារប្រតិបត្តិការនៅក្នុងបរិបទផ្សេងទៀត (ប្រទេសប៉ាគីស្ថាន) ។ មានការពិចារណាតិចតួចត្រូវបានធ្វើឡើងទៅលើទម្លាប់ធ្វើស្រែចម្ការ និងទម្លាប់គ្រប់គ្រងទឹកដែលមាននៅមុនពេលអនុវត្តគម្រោង ។ ស្រដៀងគ្នានេះដែរ ការផ្លាស់ប្តូរនៃវិសាលភាពនេះមិនត្រូវបានសម្រេចដោយឈរលើមូលដ្ឋាននៃការពិគ្រោះយោបល់ជាមួយកសិករ និងការរំពឹងចង់បានរបស់កសិករនោះដែរ ។

# ១~ ទស្សនវិស័យប្រវត្តិសាស្ត្រអំពីគម្រោង

## ១.៤- ការយឺតយ៉ាវនៅក្នុងការងារសាងសង់ និងរដូវដាំដុះសាកល្បងដំបូង

ការផ្លាស់ប្តូរវិសាលភាពក្នុងការគ្រោងប្លង់បានបង្កការយឺតយ៉ាវយ៉ាងខ្លាំងដល់ការផ្តល់សេវាធារាសាស្ត្រដល់កសិករ ដែលកាលដើមឡើយការផ្តល់សេវាកម្មនេះត្រូវបានគ្រោងទុកនៅក្នុងខែសីហា ឆ្នាំ២០០៤ ហើយដែលត្រូវពន្យារពេលទៅដល់ខែកក្កដា ឆ្នាំ២០០៦ ។ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការយឺតយ៉ាវនេះទៅលើការបង្កើត និងការពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) និងទៅលើកម្មវិធីផ្សព្វផ្សាយសិកម្ម និងនៅស្របពេលដែលប្រព័ន្ធទាំងមូលត្រូវបានអភិវឌ្ឍដែរនោះ មានការសម្រេចចិត្តផ្តល់ទឹកដល់ផ្ទៃដីស្រែសាកល្បងចំនួន ៥០ហិកតា តាមរយៈការបូម ។

ជាអកុសល ការពិសោធនេះបានបង្ហាញឱ្យឃើញនូវបញ្ហាដែលបង្កឡើងដោយដីប្រភេទដីខ្សាច់ ដែលបណ្តាលឱ្យមានការហូរទឹក និងការជ្រាបទឹកច្រើនជ្រុល ។ ឧបសគ្គបន្ថែមទៀតត្រូវបានរកឃើញភ្លាម១ដែរដូចជា : ទម្លាប់ធ្វើស្រែចម្ការតាមយថាផល សកម្មភាពមិនមែនកសិកម្មផ្សេង១របស់កសិករ និងបរិបទប្រវត្តិសាស្ត្រ គឺជាលក្ខខណ្ឌអវិជ្ជមានបន្ថែម ដែលបង្កជាបញ្ហាដល់ការអភិវឌ្ឍកសិកម្មដែលមានធារាសាស្ត្រគ្រប់គ្រាន់ និងការកែលម្អទិន្នផលស្រូវនៅក្នុងតំបន់សាកល្បង ។

នៅក្នុងឆ្នាំ២០០៧ ខណៈដែលប្រព័ន្ធត្រូវបានសាងសង់ចប់ជាស្ថាពរ កិច្ចខិតខំប្រឹងប្រែងដំបូងបង្អស់មួយដើម្បីដាំដុះស្រូវនៅក្នុងអំឡុងពេលរដូវប្រាំងត្រូវបានធ្វើឡើងនៅក្នុងតំបន់សាកល្បងដែលមានផ្ទៃដី ៨០ ហិកតា ដែលត្រូវបានរៀបចំឡើងឱ្យដំណើរការ "តាមគម្រោងប្លង់ដែលបានគ្រោង" ។ ជាថ្មីម្តងទៀត ជាអកុសល បទពិសោធន៍នេះបានបង្ហាញថា ដោយសារតែប្រភេទដីជាដីមានខ្សាច់ ការបង្ហូរទឹកពីដីស្រែមួយទៅដីស្រែមួយទៀតនឹងមិនអាចឱ្យគេគ្រប់គ្រងកម្រិតកំពស់ទឹកតាមកម្រិតដីស្រែបានឡើយ ។ ទោះបីជាស្រែត្រូវបានគេលើកភ្លឺក៏ដោយ ដីស្រែដែលស្ថិតនៅសងខាងប្រឡាយដោះទឹក ស្ងួតរីងយ៉ាងឆាប់រហ័សដោយសារតែកម្រិតនៃការហូរជ្រាបខ្ពស់នៅក្នុងប្រឡាយដោះទឹកដែលជីកជ្រៅ ។ រដូវនេះបង្កបញ្ហាដល់ភាពពាក់ព័ន្ធនៃប្រឡាយរងទីបី និងបានបង្ហាញថា ការគ្រប់គ្រងទឹកមិនអាចធ្វើទៅបានឡើយនៅកម្រិតក្បាលដីស្រែ ហេតុនេះ ហើយប្រការនេះជាបញ្ហាចោទចំពោះភាពទាក់ទងនៃគម្រោងប្លង់ប្រព័ន្ធទាំងមូល ។

នៅទីបញ្ចប់ ប្រព័ន្ធទាំងមូលត្រូវបានអ្នកម៉ៅការប្រគល់ទៅឱ្យMOWRAM នៅដំណាច់ខែមិថុនា ឆ្នាំ២០០៨ ។ ហេដ្ឋារចនាសម្ព័ន្ធដែលបានកសាងហើយទាំងនោះ រួមមាន :

- ☐ ទំនប់នៅលើស្ទឹងជីនិត ជាមួយនឹងសមត្ថភាពផ្ទុកទឹកអតិបរមាចំនួន ៧.៧៤០.០០០ ម៣ ។ ទំនប់នេះក៏រួមមានផ្លូវបង្ហូរទឹកដ៏វែងមួយផងដែរ (៧០០ម៉ែត្រ) និងផ្លូវត្រីមួយសម្រាប់ឱ្យត្រីធ្វើបម្លាស់ទី ។
- ☐ ប្រឡាយមេធំមួយ មានបណ្តោយប្រវែង ៧គីឡូម៉ែត្រ ដែលដើរតួនាទីជាប្រឡាយស្តុកទឹកបម្រុង ។
- ☐ ប្រឡាយរងទី១ចំនួន ៥ ខ្សែ ដែលផ្តល់ទឹកដល់ទីតាំងស្រែចំនួន ៤៨ ប្លុក តាមរយៈបណ្តាញប្រឡាយរងទី២ ។ ប្រឡាយរងទី១នីមួយ១ត្រូវបានបំពាក់ដោយទ្វារទឹកមួយនៅខាងចុងប្រឡាយ ដើម្បីផ្តល់លទ្ធភាពដល់ការកែតម្រូវការបញ្ចេញទឹក។ ចំណែកឯនៅខាងចុងនៃប្រឡាយរងទី២នីមួយ១ត្រូវបានបំពាក់ដោយទ្វារទឹកចំហដែលធ្វើអំពីបេតុង ដើម្បីផ្តល់បរិមាណទឹកសមាមាត្រទៅប្លុកនីមួយ១ស្របតាមទំហំដីនៃតំបន់របស់ប្លុកនោះ ។
- ☐ បណ្តាញដោះទឹក ដើម្បីបង្ហូរទឹកដែលលើសពីតម្រូវការចេញ ។

បណ្តាញធារាសាស្ត្រ និងប្រព័ន្ធដោះទឹកនេះអនុញ្ញាតឱ្យគេអាចគ្រប់គ្រងទឹកបាននៅលើតំបន់ដែលមានផ្ទៃដីប្រមាណ ២.០០០ ហិកតា របស់ប្រជាកសិករចំនួន ២.៥០០គ្រួសារ ។

# ១. ទស្សនវិស័យប្រវត្តិសាស្ត្រអំពីគម្រោង

## ១.៥- ផលប៉ះពាល់យ៉ាងឆាប់រហ័ស និងជាក់ស្តែងលើទិន្នផលស្រូវរដូវវស្សា










នៅពេលដែលការស្រោចស្រពបានចាប់ផ្តើមយ៉ាងឆាប់តាមដែលអាចនៅក្នុងតំបន់ទាំងមូល គេបានសង្កេត ឃើញថា ទិន្នផលស្រូវមានការកើនឡើងជាបន្តបន្ទាប់ (១,៦ តោន/ហិកតា នៅមុនពេលមានធារាសាស្ត្រ ១,៩ តោន/ហិកតា នៅក្នុងឆ្នាំ២០០៦ និង២,២ តោន/ហិកតា នៅក្នុងឆ្នាំ២០០៧) ។ ការកែលម្អទិន្នផលស្រូវជាមធ្យម នេះ គឺជាការជាក់ស្តែងសម្រាប់គ្រប់ប្រភេទពូជស្រូវ ប៉ុន្តែពូជស្រូវធ្ងន់ផ្តល់ទិន្នផលល្អប្រសើរជាង ។ យើងសង្កេត ឃើញថា ការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ បានធ្វើឱ្យកសិករចាប់អារម្មណ៍ឡើងវិញទៅលើប្រភេទពូជស្រូវធ្ងន់ (ប្រសិនបើគ្មានប្រព័ន្ធធារាសាស្ត្រទេ នោះហានិភ័យនៃភាពរាំងស្ងួតនៅចុងរដូវវស្សា គឺជាឧបសគ្គចម្បងមួយចំពោះប្រភេទពូជស្រូវធ្ងន់) ។ ចំនួនកសិករដែលទទួលបានផលស្រូវលើសពី ២,៥ តោន/ហិកតា កំពុងមានចំនួនកើនឡើង ប៉ុន្តែមិនទាន់ច្រើនតាមការដែលយើងបានរំពឹងទុកនៅឡើយ (នៅតិចជាង ២០% នៅឡើយ) ។

ផលប៉ះពាល់ធ្ងន់ធ្ងរកើតមាននៅកន្លែងណាដែលទទួលបានទិន្នផលមិនល្អ (SC 1, 2 និង 4) ។ ប្រការនេះ ជាការពិតនៅក្នុងប្លុកសាកល្បងនៅតាម SC1 ជាកន្លែងដែលសកម្មភាពផ្សព្វផ្សាយកសិកម្មត្រូវបានផ្តោតសំខាន់ នៅក្នុងអំឡុងពេល ៤ឆ្នាំដំបូងនៃការអនុវត្តគម្រោង (ប្រហែល ១,២ តោន/ហិកតា នៅមុនឆ្នាំ២០០៥ និង ២,២ តោន/ហិកតា នៅក្នុងឆ្នាំ២០០៧) ។ ប៉ុន្តែផ្ទុយទៅវិញ ការផ្គត់ផ្គង់ទឹក ទោះបីជាធ្វើឡើងត្រឹមត្រូវក៏ដោយ ក៏មិន បាននាំមកនូវការកែលម្អទិន្នផលឡើយ ពិសេសនៅក្នុងតំបន់ដែលទិន្នផលស្រូវគេអាចទទួលយកបានរួចទៅហើយ នៅមុនពេលអភិវឌ្ឍប្រព័ន្ធនោះ ។ ជីជាតិដី និងវិធីដាំដុះត្រូវតែគិតពិចារណាឱ្យបានដិតដល់ ប្រសិនបើយើងចង់ ឃើញការកែលម្អទិន្នផលស្រូវនៅក្នុងតំបន់ទាំងនោះ ។

# ២. ការគ្រោងប្លង់ហេដ្ឋារចនាសម្ព័ន្ធ និងការពិចារណាសម្រាប់ការសាងសង់

## ២.១- ការគ្រោងប្លង់/ការចាប់ផ្ដើម

- ***ការធ្វើអង្កេតឋានលេខាមិនគ្រប់គ្រាន់***

កង្វះទិន្នន័យឋានលេខាដែលអាចជឿជាក់បានក្នុងអំឡុងពេលនៃដំណើរការគ្រោងប្លង់បានបណ្ដាលឱ្យមានការដកផ្ទៃដី ៤០០ ហិកតា (ប្រហែល ២០% នៃផ្ទៃដីដែលបំពាក់ធារាសាស្ត្រទាំងមូល) ចេញពីសេវាដែលមានប្រសិទ្ធភាព ។ ទីខ្ពស់ៗដែលទឹកមិនអាចហូរទៅដល់ ឬផ្ទុយទៅវិញនៅតាមវាលស្រែនៅកន្លែងទាបកសិករជួបប្រទះបញ្ហាដក់ទឹកដែលរារាំងដល់ការដាំដុះ ដែលបញ្ហានេះ គឺបណ្ដាលមកពីការគិតពិចារណាមិនបានគ្រប់គ្រាន់ទៅលើភាពខុសគ្នានៃស្ថានភាពឋានលេខានៅក្នុងតំបន់គម្រោង ។ បញ្ហានេះក៏បណ្ដាលឱ្យថ្លៃចំណាយទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗកើនឡើងផងដែរ ។

- ***ផលប៉ះពាល់នៃគុណភាពដី***

គោលគំនិតនៃគម្រោងប្លង់ដែលត្រូវបានស្នើឡើង និងអនុម័តនៅក្នុងអំឡុងពេលនៃការផ្លាស់ប្ដូរវិសាលភាព បានផ្ដោតការពិចារណាតិចតួចទៅលើប្រភេទដីដែលមានខ្សាច់នៅក្នុងតំបន់គម្រោងនោះ ។ ដូចក្នុងគំរូជាច្រើននៅក្នុងតំបន់អេកូឡូស៊ី-កសិកម្មស្រដៀងគ្នា (វាលស្រែជួរកណ្ដាលនៅផ្នែកខាងកើតនៃទន្លេសាប) ដីមិនមានគុណភាពស័ក្ដិសម ឡើយ ។ ដីនៅកន្លែងនោះមានកម្រិតសរីរាង្គទាប សមត្ថភាពផ្លាស់ប្ដូរកាចុង (Cationic) ទាប និងភាពមានជម្រាបទឹកខ្ពស់ ។

នៅក្នុងបរិបទនៃការសិក្សាដីនេះ ការជីកប្រឡាយដោះទឹកបានបណ្ដាលឱ្យមានការហូរច្រោះដីស្រែដែលរំខានដល់ការគ្រប់គ្រងទឹកនៅតាមដីស្រែនីមួយៗ ។

- ***ប្រឡាយរងទី៣: ផលប៉ះពាល់ទៅលើថ្លៃចំណាយប្រតិបត្តិការ***

គម្រោងប្លង់ត្រូវបានផ្អែកលើការអភិវឌ្ឍបណ្ដាញប្រឡាយរងទី៣ និងប្រព័ន្ធប្រឡាយដោះទឹកប្រវែង ១៥០គីឡូម៉ែត្រ ដែលត្រូវសាងសង់ និងគ្រប់គ្រងដោយកសិករនៅតាមប្លុកនីមួយៗ ។ ប្រភេទធារាសាស្ត្រនេះតម្រូវឱ្យមានប្រភេទថ្មីមួយក្នុងការរៀបចំចងក្រងកសិករ និងការបង្កើតវេនចែកទឹក ដែលមិនសូវសមស្របជាមួយនឹង (១) ទម្លាប់យថាកម្មរបស់កសិករ (២) ថ្លៃចំណាយលើប្រភេទនៃការចែកចាយទឹកបែបនេះ និង (៣) ការផ្សព្វផ្សាយអំពីការកាន់កាប់ដីរបស់កសិករនៅក្នុងតំបន់ប្រព័ន្ធស្រោចស្រព ។

# ២. ការគ្រោងប្លង់ហេដ្ឋារចនាសម្ព័ន្ធ និងការពិចារណាសម្រាប់ការសាងសង់



- ***ថ្លៃចំណាយលើការថែទាំ***

ការថែទាំហេដ្ឋារចនាសម្ព័ន្ធទំនងជាបញ្ហាប្រឈមដ៏ចម្បងមួយចំពោះនិរន្តរភាពរបស់គម្រោង SCIRIP ។ ការហូរច្រោះដាច់ហេដ្ឋារចនាសម្ព័ន្ធមានកម្រិតខ្ពស់ ដែលត្រូវបានសង្កេតឃើញដោយសារ (១)- ប្រព័ន្ធដោះទឹក និងប្រឡាយកិនបង្ហាប់មិនបានល្អ (២)- ជម្រើសផ្នែកបច្ចេកទេសដែលធ្វើឡើងនៅក្នុងអំឡុងពេលនៃការគ្រោងប្លង់ ដែលប្រែក្លាយទៅជាប្រឡាយរងទី១មានកម្រិតខ្ពស់ជាងកម្រិតដីស្រែ និង ជិតគ្នាទៅនឹងប្រព័ន្ធដោះទឹកដែលងាយប្រឈមនឹងហានិភ័យនៃការជ្រាប និងហូរច្រោះខ្ពស់ (៣)- ដង់ស៊ីតេនៃការបម្លាស់ទីសត្វពាហនៈមានកម្រិតខ្ពស់ និង (៤)- ការឱ្យសត្វពាហនៈដើរស៊ីស្មៅនៅក្នុងតំបន់គម្រោង និងដីមានអត្រាជម្រាបទឹកខ្ពស់ ។ ការហូរច្រោះដាច់ហេដ្ឋារចនាសម្ព័ន្ធនេះ បានបណ្តាលឱ្យការចំណាយទៅលើការថែទាំកើនឡើងខ្ពស់ ។ សម្រាប់ឆ្នាំទី១នៃការគ្រប់គ្រងគម្រោង ទឹកប្រាក់សរុបដែលចំណាយដោយ FWUC គឺខ្ពស់ដែលមានរហូតដល់ទៅ ៤០ លានរៀល (១០.000 ដុល្លារសហរដ្ឋអាមេរិក) ដែលស្មើនឹងចំណាយសរុប ៥ ដុល្លារ/ហិកតា សម្រាប់រចនាសម្ព័ន្ធប្រឡាយរង ទី២ ទោះបីជាបណ្តាញចែកចាយនេះទើបតែសាងសង់រួចថ្មីក៏ដោយ ។

- ***សមត្ថភាពរបស់អ្នកម៉ៅការក្នុងមូលដ្ឋាន និងការត្រួតពិនិត្យសំណង់មិនបានគ្រប់គ្រាន់***

ហេដ្ឋារចនាសម្ព័ន្ធដែលរចនាប្លង់ដោយក្រុមហ៊ុនប្រឹក្សាយោបល់អន្តរជាតិ តម្រូវឱ្យមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់បំផុត ។ សំណង់ច្រកទ្វារបង្ហូរទឹកធ្វើពីបេតុងក្រិតខ្នាតយ៉ាងត្រឹមត្រូវដូចគ្នាដែរចំពោះការធ្វើប៉ានលេខា ព្រមទាំងពុំនុះកាត់ទទឹងនៃប្រឡាយរងទី១ដែលធ្វើត្រឹមត្រូវតាម "ប្លង់" នឹងផ្តល់នូវលំហូរជាក់លាក់ និងសមាមាត្រត្រឹមត្រូវទៅដល់ប្រឡាយរងទី២ដែលគោរពតាមគម្រោងប្លង់នៃពុំនុះកាត់ទទឹងប្រឡាយ ។ ជាអកុសល ក្រុមហ៊ុនសាងសង់ក្នុងស្រុកពុំមានចំណេះធ្វើផ្នែកបច្ចេកទេស និងបច្ចេកវិទ្យាគ្រប់គ្រាន់ដើម្បីគោរពតាមបទដ្ឋានដ៏ខ្ពស់នៃការសាងសង់បែបនេះទេ ។ ការអង្កេតប៉ានលេខាដែលធ្វើឡើងនៅក្នុងឆ្នាំ២00៦ បានបង្ហាញឱ្យឃើញថា ប្រឡាយរងទី១ទាំងអស់មិនបានគោរពតាមលក្ខខណ្ឌតម្រូវនៃគម្រោងប្លង់ឡើយ ។ ជាងនេះទៅទៀត ការត្រួតពិនិត្យការងារសាងសង់ពុំបានធ្វើឡើងគ្រប់គ្រាន់ទេនៅក្នុងរយៈពេលនៃការសាងសង់ទាំងមូល ។

# ២. ការគ្រោងប្លង់ហេដ្ឋារចនាសម្ព័ន្ធ និងការពិចារណាសម្រាប់ការសាងសង់

## ២.២- លទ្ធភាពរបស់កសិករក្នុងភាពធ្វើជាម្ចាស់លើហេដ្ឋារចនាសម្ព័ន្ធ




- ***គំរូធារាសាស្ត្រ និងប្រព័ន្ធដោះទឹក : គំនិតថ្មីមួយសម្រាប់កសិករនៅក្នុងតំបន់គម្រោង***

ដូចដែលបានលើកឡើងខាងលើ ទម្លាប់កសិកម្មជាប្រពៃណីពឹងផ្អែកទៅលើការគ្រប់គ្រងទឹកជំនន់ និងការត្រួតពិនិត្យស្រទាប់ទឹកតាមរយៈបណ្តាញប្រឡាយ ដែលក៏នឹងដើរតួជាប្រព័ន្ធដោះទឹកនៅពេលទឹកជំនន់ស្រកចុះទៅ វិញ ។ ទម្លាប់អនុវត្តន៍ទាំងនេះពុំមែនមានតែនៅក្នុងតំបន់គម្រោងស្ទឹងជីនិតប៉ុណ្ណោះនោះទេ ប៉ុន្តែគឺជា ទម្លាប់ទូទៅនៅតាមដងទន្លេសាប និងអាងទន្លេមេគង្គក្រោម ។ ការបែងចែកដាច់ពីគ្នារវាងប្រឡាយ និងបណ្តាញដោះទឹកត្រូវបានដាក់ឱ្យអនុវត្តជា "កញ្ចប់បច្ចេកទេស" ថ្មីនៅក្នុងគម្រោង SCIRIP ដោយមានការពិគ្រោះយោបល់តិចតួចជាមួយកសិករ ។ រដូវស្រោចស្រពដំបូងបានបញ្ជាក់អំពីការយល់ដឹងរបស់កសិករដែលមើលឃើញថា ប្រព័ន្ធដោះទឹកនេះបានបង្កនូវការបាត់បង់ទឹកកម្រិតខ្ពស់តាមរយៈការហូរច្រោះ និងការហូរជ្រាប ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺថា កសិករគ្មានជម្រើសអ្វីក្រៅពីកម្រិតបាតុភូតនេះដោយធ្វើការបិទប្រឡាយដោះទឹក ដូច្នេះ វាជាការវិលត្រឡប់ទៅរកវិធីគ្រប់គ្រងទឹកតាមទំនៀមទម្លាប់នៃការវាតទីរបស់ទឹកជំនន់ តាមរយៈប្រឡាយ និងចង្អូរដោះទឹក ។

## ២. ការគ្រោងប្លង់ហេដ្ឋារចនាសម្ព័ន្ធ និងការពិចារណាសម្រាប់ការសាងសង់

- *សកម្មភាពជាច្រើនរបស់កសិករ : ឧបសគ្គចម្បងចំពោះទម្លាប់ដែលត្រូវការកម្លាំងពលកម្មច្រើន*

សកម្មភាពកសិកម្ម និងសកម្មភាពក្រៅពីកសិកម្មជាច្រើនរបស់កសិករនៅក្នុងតំបន់គម្រោង អាចត្រូវបាន ចាត់ទុកជាឧបសគ្គមួយទៀតចំពោះការអនុវត្តកញ្ចប់បច្ចេកវិទ្យាដែលបានស្នើឡើងដោយគម្រោង ។ ទីមួយ ការចែកចាយទឹកតាមប្រឡាយរងទី៣ តម្រូវឱ្យមានការប្រមូលកម្លាំងពលកម្មច្រើន ដែលមិនសមស្របនឹងប្រភេទនៃការដាំដុះយថាផលដែលមានតាំងពីមុនមកនៅក្នុងតំបន់ស្ទឹងជីនិត ។

ក្រៅពីនេះ ដោយសារការមិនអាចគ្រប់គ្រងទឹកនៅតាមក្បាលដីស្រែនីមួយៗ កសិករត្រូវបានតម្រូវឱ្យរៀបចំប្រតិទិនដាំដុះឱ្យមានភាពស៊ីសង្វាក់គ្នានៅកម្រិតជាប្លុក ។ ការធ្វើ ដូច្នេះត្រូវបានរារាំងដោយការប្រមូលកម្លាំងពលកម្មស្របពេលជាមួយគ្នានៅក្នុងប្រព័ន្ធដាំដុះផ្សេងទៀតនៅក្នុងតំបន់នេះ ។

- *ព្រំដែនទឹក និងព្រំដែនរដ្ឋបាល : ផលប៉ះពាល់ទៅលើការប្រមូលផ្តុំរបស់កសិករ*

ដូចដែលអ្វីដែលត្រូវបានសង្កេតឃើញនៅក្នុងប្រព័ន្ធធារាសាស្ត្រ "ទំនើប" ធំៗ ព្រំដែនទឹកនៃហេដ្ឋរចនាសម្ព័ន្ធស្ទឹងជីនិតមិនគ្របពីលើព្រំដែនរដ្ឋបាលរបស់ភូមិ និងឃុំឡើយ ។ ប្រឡាយ រងទី១គឺជាតំបន់គោលដៅរបស់ឃុំជាច្រើនចំណែកឯប្រឡាយរងទី២ផ្តល់ទឹកដល់ភូមិជាច្រើន ។ លើសពីនេះទៅទៀត គ្រួសារភាគច្រើនបំផុតកាន់កាប់ដីស្រែដែលមានទីតាំងស្ថិតនៅក្នុងតំបន់គោលដៅដែលមានប្រឡាយរងទី១ច្រើនជាងមួយ ។ ដូច្នេះម្ចាស់ដីនៅក្នុងប្លុកតែមួយមិនបង្ហាញឱ្យឃើញនូវសាមគ្គីភាពសង្គមណាមួយដែលជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបានរឹងមាំនោះឡើយ ។ ផ្ទុយទៅវិញ បញ្ហានេះបណ្តាលឱ្យមានការលំបាកក្នុងការពិគ្រោះយោបល់ជាមួយកសិករនៅកម្រិតភូមិ ។ ការសម្រេចចិត្តសំខាន់ៗដូចជា ទីតាំង និងការសាងសង់ ប្រឡាយរងទី២ និងប្រឡាយរងទី៣ ដែលតម្រូវឱ្យមានការរៀបចំការប្រជុំជាច្រើនលើកនៅក្នុងគ្រប់ភូមិដែលគ្របដណ្តប់ដោយហេដ្ឋរចនាសម្ព័ន្ធរៀងខ្លួន ។

យើងគួរទទួលស្គាល់ថា ការជៀសវាងនូវភាពខុសគ្នារវាងព្រំដែនទឹក និងព្រំដែនរដ្ឋបាល ពិតជាពិបាកនឹងធ្វើទៅកើតណាស់ ។ ប៉ុន្តែ ផលប៉ះពាល់អវិជ្ជមានអាចនឹងត្រូវរឹតត្បិតបានតាមរយៈការគូសខណ្ឌប្លុកនៃប្រឡាយរងទី២នៅតាមព្រំដែនភូមិ ។

# ៣~ ការគាំទ្រដល់ការបង្កើត និងការពង្រឹង ស.ក.ប.ទ (FWUC)

## ៣.១-ការបែងចែកការទទួលខុសត្រូវ : រដ្ឋាភិបាល/កសិករ

- *ការបែងចែកការទទួលខុសត្រូវរវាងកសិករ និងរដ្ឋាភិបាល*

ការបែងចែកការទទួលខុសត្រូវរវាងភាគីពាក់ព័ន្ធត្រូវបានកំណត់តាំងពីដំណាក់កាលដំបូង : រដ្ឋាភិបាល តាមរយៈក្រសួងរបស់ខ្លួន និងបន្ទាប់មកទៀត តាមរយៈមន្ទីរថ្នាក់ខេត្តរបស់ខ្លួន កំពុងផ្តោតការយកចិត្តទុកដាក់ទៅលើការស្តុក និងគ្រប់គ្រងទឹក និងការបែងចែកទឹកដោយត្រឹមត្រូវ និងយុត្តិធម៌រវាងសហគមន៍ផ្សេងៗគ្នា ។ ការទទួលខុសត្រូវរបស់រដ្ឋាភិបាលរួមមានដូចជា ប្រតិបត្តិការ និងការគ្រប់គ្រងអាងទឹក និងប្រឡាយមេ ព្រមទាំងហេដ្ឋរចនាសម្ព័ន្ធទាំងអស់ដែលទាក់ទង ។ នៅចុងបញ្ចប់នៃដំណាក់កាលសាងសង់ ការគ្រប់គ្រងបណ្តាញចែកចាយទឹក (ពី ប្រឡាយរងទី១ ទៅក្បាលដីស្រែនីមួយៗទាំងអស់) ត្រូវបានប្រគល់ទៅឱ្យកសិករ តាមរយៈការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។

- *មន្ទីរធនធានទឹក (PDOWRAM) និងគណៈកម្មាធិការ CRIC : តួអង្គនៅមូលដ្ឋានដែលកំពុងលេចឡើង*

រវាងកម្រិតរដ្ឋាភិបាលដែលគ្រប់គ្រងធនធានទឹកនៅកម្រិតជាតិ ស្ថាបនារចនាសម្ព័ន្ធស្តុកទឹក និងប្រឡាយមេ ហើយនិងកសិករដែលគ្រប់គ្រងទឹកនៅកម្រិតមូលដ្ឋាន តម្រូវការនូវការសម្របសម្រួលមួយដែលកើតមានឡើង : ការកែតម្រូវកម្រិតទឹក ប្រតិទិនថែទាំ និងប្រតិបត្តិការ ។ ដោយពិចារណាទៅលើគម្លាតទាំងនេះ សេចក្តីសម្រេចដំបូងបង្អស់របស់ក្រសួងធនធានទឹក គឺត្រូវប្រគល់កិច្ចប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធមេ ទៅឱ្យមន្ទីរធនធានទឹកនៅថ្នាក់មូលដ្ឋានរបស់ក្រសួង ។ SCTU ត្រូវបានផ្ទេរទៅឱ្យ PDOWRAM ហើយ PDOWRAM បានចាត់តាំងបុគ្គលិករបស់ខ្លួនឱ្យទៅធ្វើការនៅស្ទឹងជីនិត ប៉ុន្តែ រហូតមកទល់នឹងបច្ចុប្បន្ននេះ ពុំទាន់មានការបែងចែកមធ្យោបាយដើម្បីផ្តល់លទ្ធភាពដល់ការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព និងការថែទាំអាងស្តុកទឹក និងហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនៅឡើយទេ ។ ក្នុងអំឡុងពេលអន្តរកាលនេះ និងដោយសារមានការគាំទ្រពី AFD ផងនោះ FWUC កំពុងចូលរួមបង់វិភាគទានដល់ថ្លៃចំណាយសម្រាប់ការថែទាំជាប្រចាំដល់ហេដ្ឋារចនាសម្ព័ន្ធមេ ។

បន្ទាប់មក CRIC (គណៈកម្មាធិការធារាសាស្ត្រអាងស្តុកទឹកស្ទឹងជីនិត) ត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់កិច្ចសម្របសម្រួលរវាង PDOWRAM និង FWUC ប៉ុន្តែក៏ដើម្បីបំផុសឱ្យក្រុមប្រឹក្សាឃុំសង្កាត់ និងអាជ្ញាធរស្រុកចូលរួមនៅក្នុងការដឹកនាំការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រទាំងមូល ។ គណៈកម្មាធិការនេះមានលក្ខន្តិកៈលក្ខន្តិកៈផ្ទាល់ខ្លួន ដែលបញ្ជាក់អំពីការចែករំលែកការទទួលខុសត្រូវរវាង PDOWRAM និង FWUC ហើយគណៈកម្មាធិការនេះផ្តល់ការទទួលខុសត្រូវដល់ឃុំសង្កាត់ និងស្រុក ដើម្បីគាំទ្រដល់ FWUC និង PDOWRAM ។ គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដោយដីកាដែលចេញដោយអភិបាលខេត្ត ។ នៅក្នុងក្របខ័ណ្ឌបែបនេះ FWUC បានសម្រេចចិត្តផ្ទេរទៅឱ្យឃុំ/សង្កាត់នូវ កិច្ចការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ (ISF) ។ គណៈកម្មាធិការ CRIC បានបង្ហាញឱ្យឃើញនូវការគាំទ្រពិតប្រាកដរបស់ខ្លួនដល់ FWUC ក្នុងការទំនាក់ទំនងជាមួយកសិករដោយស្វែងរកអំណាចថែមទៀត ប៉ុន្តែថែមទាំងនៅក្នុងការទំនាក់ទំនងជាមួយនឹងក្រសួង ដោយប្រមូលការគាំទ្រផ្នែកនយោបាយផងដែរ ។ CRIC អាចដើរតួនាទីចម្បងនៅក្នុងពេលអនាគតក្នុងការស្វែងរកមូលនិធិពីម្ចាស់ជំនួយអន្តរជាតិសម្រាប់ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនេះនាពេលអនាគត ។

# ៣_ ការគាំទ្រដល់ការបង្កើត និងការពង្រឹង ស.ក.ប.ទ (FWUC)

- *ការផ្ទេរការគ្រប់គ្រង ឬការចែករំលែកការគ្រប់គ្រង ?*

ដំណើរការនៅស្ទឹងជីនិតនាំឆ្ពោះទៅរកការចែករំលែកការគ្រប់គ្រង ។ PDOWRAM ក្នុងនាមក្រសួង នឹងត្រូវចូលរួមនៅក្នុងការផ្តល់ការគាំទ្រប្រកបដោយប្រសិទ្ធភាពដល់ការគ្រប់គ្រងហេដ្ឋរចនាសម្ព័ន្ធមេ ។

ការចែករំលែកការទទួលខុសត្រូវនេះ គួរត្រូវបានគិតគូរតាំងពីដំណាក់កាលដំបូងនៃគម្រោង : ក្រសួងបានផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើការអភិវឌ្ឍអាងស្តុកទឹក និងប្រឡាយមេ នៅពេលដែលតួអង្គនៅមូលដ្ឋានគួរត្រូវទទួលរ៉ាប់រងលើការអភិវឌ្ឍន៍បណ្តាញចែកចាយទឹកសម្រាប់ការស្រោចស្រព ដោយមានការគាំទ្រផ្នែកបច្ចេកទេសមួយចំនួន (ពី PDOWRAM ជាឧទាហរណ៏) ។ ការពិគ្រោះ យោបល់ដ៏ច្រើនជាមួយកសិករ ត្រូវបានគ្រោងទុកនៅក្នុងដំណាក់កាលដំបូងនៃគម្រោង ដើម្បីគាំទ្រការស្តារប្រព័ន្ធធារាសាស្រឡើងវិញ ។ ប៉ុន្តែប្រការនេះមិនបាន ទទួលជោគជ័យទេ ពីព្រោះលទ្ធផលនៃការពិគ្រោះយោបល់នេះត្រូវបានចាត់ទុកថា ជាការកើតចេញពីផ្នែក "ទន់" ចំណែកឯការធ្វើសេចក្តីសម្រេចចិត្តស្តីពីគម្រោងប្លង់ហេដ្ឋារចនាសម្ព័ន្ធពឹងផ្អែកជាចម្បងទៅលើជម្រើសផ្នែកបច្ចេកទេសដែលធ្វើឡើងដោយផ្នែក "រឹង" នៃគម្រោង ។ កង្វះការសម្របសម្រួលរវាងផ្នែកទាំងពីររបស់គម្រោងនេះ និងអវត្តមាននៃតួអង្គមួយដែលមានការយល់ដឹងទូទៅអំពីគម្រោងទាំងមូល ដែលត្រូវបានពិពណ៌នាបន្ថែមនៅផ្នែកខាងក្រោមនេះ ក៏រារាំងដល់ការដាក់បញ្ចូលមតិយោបល់របស់កសិករទៅក្នុងគម្រោងប្លង់បច្ចេកទេសរបស់គម្រោង ផងដែរ ។

# ៣. ការគាំទ្រដល់ការបង្កើត និងការពង្រឹង ស.ក.ប.ទ (FWUC)

## ៣.២- ស.ក.ប.ទ (FWUC) : ភាគីពាក់ព័ន្ធដែលមានលក្ខណៈវិជ្ជាជីវៈ




### ▪ *រចនាសម្ព័ន្ធរបស់ FWUC*

រចនាសម្ព័ន្ធរបស់ FWUC នៅស្ទឹងជីនិត ត្រូវបានធ្វើឱ្យមានលក្ខណៈវិជ្ជាជីវៈដោយអន្លើ ។ រចនាសម្ព័ន្ធនេះរួមមាន តំណាងកសិករដែលត្រូវបានជ្រើសតាំង តាមរយៈសន្និបាតនៃតំណាងភូមិចំនួន ២៤ រូប សម្រាប់ការធ្វើសេចក្ដីសម្រេច ក្រោមការដឹកនាំដោយគណៈកម្មាធិការមួយដែលមានសមាជិក ៥ រូប ដែលជាគណៈកម្មាធិការគ្រប់គ្រង និងក្រុមការងារស្នូល ដែលមានសមាជិកជាបុគ្គលិកទទួលប្រាក់ខែ ៤ រូប អ្នកយាមល្បាតប្លុក ១៥ រូប និងកម្មករអចិន្ត្រៃយ៍ ៤ រូប ។

ក្រុមការងារនេះត្រូវបានបង្កើតឡើងនៅក្រោយដំណើរការសាកល្បងដ៏វែង និងការផ្ទេរការទទួលខុសត្រូវដោយរលូនពីក្រុមគម្រោងទៅឱ្យ FWUC ។ បច្ចុប្បន្ន គម្រោងបានដកចេញនូវការគាំទ្ររបស់ខ្លួន ហើយសមត្ថភាពក្រុមរចនាសម្ព័ន្ធ FWUC បច្ចុប្បន្ន និងបុគ្គលិក គឺជាតម្រូវការចាំបាច់សម្រាប់ការគ្រប់គ្រងពេញលេញទៅលើប្រព័ន្ធធារាសាស្ត្រនេះ ។

## ៣. ការគាំទ្រដល់ការបង្កើត និងការពង្រឹង ស.ក.ប.ន (FWUC)

- *លទ្ធភាពរបស់ FWUC ក្នុងការទទួលយកការកិច្ចទទួលខុសត្រូវរបស់ខ្លួន*

យុទ្ធនាការលើកទីបីស្តីពីការស្រោចស្រពបំពេញបន្ថែមស្រូវរដូវវស្សាកាលពីរដូវវស្សាកន្លងទៅ បានបង្ហាញឱ្យឃើញច្បាស់ថា ក្រុម FWUC ទទួលបានការគ្រប់គ្រងប្រព័ន្ធនេះពេញលេញនៅក្នុងដែសម្រាប់ការដំណើរការ និងសម្រាប់ការថែទាំ ។ ប្រព័ន្ធទាំងមូលត្រូវបានបន្តដំណើរការសម្រាប់យុទ្ធនាការទាំងមូល និងបានមកដល់ទីបញ្ចប់ជាមួយនឹងតម្រូវការសម្រាប់ការថែទាំខួបតិចតួចតែប៉ុណ្ណោះ ។ ការថែទាំទាំងនោះត្រូវបានគេប៉ាន់ប្រមាណ ហើយការងារថែទាំត្រូវបានធ្វើចប់សព្វគ្រប់ទាន់ពេលវេលា ដើម្បីត្រៀមលក្ខណៈសម្រាប់យុទ្ធនាការនៅរដូវប្រាំង ។

ម្យ៉ាងទៀត ការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រត្រូវបានធ្វើឡើងប្រកបដោយជោគជ័យ ដោយមានការចាត់ចែងរួមគ្នាជាមួយអាជ្ញាធរមូលដ្ឋាន ។

បច្ចុប្បន្នក្រុមការងាររបស់គម្រោងកំពុងដកការគាំទ្រពីការងារដំណើរការ និងកិច្ចការថែទាំ ។ ការគាំទ្របន្ថែម នៅតែត្រូវការជាចាំបាច់សម្រាប់កិច្ចការជំនាញជាច្រើនថែមទៀត ជាពិសេសកិច្ចការដែលទាក់ទងនឹងឧបករណ៍ដែលប្រើដោយកុំព្យូទ័រ : ប្រព័ន្ធទិន្នន័យអំពីម្ចាស់/សមាជិក ការធ្វើវិក្កយបត្រ ISF ការត្រួតពិនិត្យគណនេយ្យ និងការធ្វើរបាយការណ៍ទៅឱ្យ ម្ចាស់ជំនួយ ។ គម្រោង នឹងបន្តគាំទ្រដល់ FWUC តាមសំណើរបស់ពួកគេ តាមរយៈការផ្តល់សេវាជាក់លាក់ ។ ប្រព័ន្ធតាមដាន និងវាយតម្លៃមួយត្រូវបានបង្កើតឡើងដើម្បីតាមដាន និងជួយសម្រួលដល់វឌ្ឍនភាពឆ្ពោះទៅរកស្វ័យភាពរបស់ FWUC ។

- *ការព្រមព្រៀងស្តីពីសេវាកម្មធារាសាស្ត្រ*

ការបង្កើតរចនាសម្ព័ន្ធ FWUC កើតចេញពីការកំណត់និយមន័យសេវាកម្មធារាសាស្ត្រមួយដែលកសិករបានព្រមព្រៀងបង់ថ្លៃឱ្យ ។ ការពិភាក្សាដ៏វែងត្រូវបានធ្វើឡើងជាជំហានដំបូង ដើម្បីគិតគូរអំពីសេវាដែលត្រូវផ្តល់ឱ្យ ដោយប្រើប្រាស់ប្រព័ន្ធ ដូចដែលគម្រោងនេះត្រូវបានប្រគល់ឱ្យដោយក្រសួងដូច្នោះដែរ ។ តើការគ្រប់គ្រងអាចទៅដល់កម្រិតណា : កម្រិតប្រឡាយរងទី១ រងទី២ រងទី៣ ? គ្មានសេវាកម្មសមហេតុផលណាដែលអាចកំណត់ដើម្បីឱ្យ FWUC គ្រប់គ្រងតាមតម្លៃរំពឹងទុករបស់កសិករឡើយ ។

នៅទីបំផុត ការព្រមព្រៀងត្រូវបានធ្វើឡើងនៅពេលដែលយើងបានយល់ច្បាស់ថា គម្រោងនេះត្រូវតែកែសម្រួលឱ្យស្របទៅនឹងសេវាដែលកសិករត្រូវការ និងមិនផ្ទុយពីនេះ : ការផ្តល់ទឹកបន្ថែមសម្រាប់ការដាំដុះស្រូវរដូវវស្សាផ្តល់លទ្ធភាពដល់ការដាំដុះប្រភេទពូជស្រូវធ្ងន់ ដោយមិនចាំបាច់មានការចូលរួមដែលកសិករត្រូវចំណាយពេលច្រើននោះ ។ ដូច្នេះហើយ ហេដ្ឋា-រចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រត្រូវបានពិនិត្យឡើងវិញដើម្បីអនុញ្ញាតឱ្យគេអាចគ្រប់គ្រងទឹកជំនន់បាន ។ ប្រការនេះធ្វើឱ្យហេដ្ឋរចនាសម្ព័ន្ធប្រឡាយរងទី៣បែទៅជាគ្មានប្រយោជន៍ លើកលែងតែក្នុងលក្ខខណ្ឌភូមិសាស្ត្រលំបាកៗ និងផ្តោតប្រតិបត្តិការទៅលើការគ្រប់គ្រងប្រព័ន្ធដោះទឹកជាងទៅលើការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក ។ រចនាសម្ព័ន្ធ FWUC ត្រូវបានបង្កើតឡើងស្របទៅតាម នោះដែរ ជាមួយនឹងចំនួនអ្នកយាមល្បាតប្លុកដែលមានចំនួនកំណត់មួយដែលផ្តល់លទ្ធភាពដល់ការគ្រប់គ្រងទឹកបានល្អនៅស្ទើរគ្រប់ទីកន្លែង ។

យើងប្រហែលជាចំណាយពេលវេលា និងប្រាក់តិចជាងនេះ ប្រសិនបើប្រព័ន្ធនេះត្រូវបានគេរៀបចំគ្រោងប្លង់ដូច្នេះតាំងពីដើមដំបូងមក ។

# ៣_ ការគាំទ្រដល់ការបង្កើត និងការពង្រឹង ស.ក.ប.ឧ (FWUC)

## ៣.៣-ថវិកា ថ្លៃសេវាកម្ម ISF និងការគ្រប់គ្រងប្រកបដោយនិរន្តរភាព







- ***តម្រូវការថវិកា***

ការចំណាយបច្ចុប្បន្នសម្រាប់កិច្ចដំណើរការរបស់ FWUC ត្រូវបានពណ៌នាសង្ខេបដូចខាងក្រោម :

ការគ្រប់គ្រងប្រព័ន្ធបច្ចុប្បន្ន (២.000 ហិកតា) អាចកាត់បន្ថយមកនៅត្រឹម ៤0.000 ដុល្លារសហរដ្ឋអាមេរិក ដោយរឹតត្បិតថវិកាត្រឹមតែកម្រិតអប្បបរមាដែលចាំបាច់បំផុត ។ ដោយផ្អែកលើផែនការនេះ កិច្ចព្រមព្រៀងលើកទីមួយត្រូវបានធ្វើឡើងជាមួយម្ចាស់ជំនួយដើម្បីគាំទ្រឧបត្ថម្ភកធនដែលថយចុះជាលំដាប់ (៤0.000 ដុល្លារសហរដ្ឋអាមេរិក នៅក្នុង ឆ្នាំ២00៨ ៣0.000 ដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ២00៩ ២0.000 ដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ២0១0 និង ១0.000 ដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ២0១១) ។

ថវិកាមួយភាគបីប៉ុណ្ណោះ ដែលត្រូវបានចំណាយទៅលើប្រតិបត្តិការ និងការថែទាំ (O&M) ហើយពាក់កណ្តាលនៃថវិកាទាំងមូលត្រូវគាំទ្រការចំណាយលើប្រាក់បៀវត្សរ៍ និង ប្រាក់ឧបត្ថម្ភនានាសម្រាប់រចនាសម្ព័ន្ធស្នូល ។ ថ្លៃចំណាយលើរចនាសម្ព័ន្ធ គឺជាបញ្ហាចោទ លើកលែងតែថ្លៃចំណាយនោះត្រូវបានគាំទ្រដោយការឧបត្ថម្ភកធន ។ នៅពេលដែលកសិករត្រូវតែបង់ប្រាក់ចំណាយនេះ FWUC ក៏ត្រូវតែត្រៀមខ្លួនជាស្រេចដើម្បីផ្តល់ហេតុផល ។

ចាប់ពីឆ្នាំ២00៦ រហូតមកដល់បច្ចុប្បន្ននេះ ការចំណាយសម្រាប់ការគ្រប់គ្រងប្រព័ន្ធមានការថយចុះជាលំដាប់ និងទទួលបានប្រសិទ្ធភាពដូចដែលបង្ហាញនៅក្នុងរូបក្រាហ្វិក ។ គេរំពឹងទុកថា នៅឆ្នាំ២0១២ FWUC នឹងអាចគ្រប់គ្រងប្រព័ន្ធនេះដោយប្រើប្រាស់ចំណូលផ្ទាល់ខ្លួនពីការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ (ISF) ។

# ៣. ការគាំទ្រដល់ការបង្កើត និងការពង្រឹង ស.ក.ប.ធ (FWUC)

- ***ថ្លៃសេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ (ISF)***

អត្រា ISF សម្រាប់យុទ្ធនាការឆ្នាំ២០០៧ ត្រូវបានកំណត់ត្រឹម ២០.០០០ រៀល/១ហិកតា និងប្រមូលនៅចន្លោះខែមករា និងខែសីហា ឆ្នាំ២០០៨ ។ ចំនួនប្រាក់សរុបដែលប្រមូលបាន គឺ ៣៤ លានរៀល (៨.៥០០ ដុល្លារសហរដ្ឋអាមេរិក) ស្មើនឹង ៨៥% នៃចំនួនប្រាក់សរុបដែលត្រូវប្រមូល និងស្មើ ៩៥% នៃចំនួនអ្នកទទួលផលសរុប ។ អត្រានេះនឹងកើនឡើង ដល់ទៅ ២៥.០០០ រៀល (៦,២៥ ដុល្លារសហរដ្ឋអាមេរិក) ក្នុងមួយហិកតា ក្នុងឆ្នាំ២០០៩ ហើយនឹងកើនឡើងដល់ ៦០.០០០ រៀល/១ហិកតា (១៥ ដុល្លារសហរដ្ឋអាមេរិក) នៅក្នុងឆ្នាំ២០១៣ នេះបើតាមការគិតគូរទុកនាពេលបច្ចុប្បន្នរបស់កសិករ ។ ចំណូលទាំងនេះរ៉ាប់រងបានប្រមាណ ២០% នៃការចំណាយបច្ចុប្បន្ន របស់ FWUC ហើយនឹងរ៉ាប់រងបានប្រហែល ៧៥% នៃថវិកានៅក្នុងឆ្នាំ២០១៣ តាមលំហូរចំណាយបច្ចុប្បន្នសម្រាប់គោលដៅដដែល (២.០០០ ហិកតា) ។




ដើម្បីដោះស្រាយបញ្ហាគម្លាតហិរញ្ញវត្ថុដែលរំពឹងទុក ដំណោះស្រាយជាច្រើនអាច នឹងត្រូវពិចារណា :

១. បង្កើនតំបន់នៃប្រព័ន្ធដើម្បីបង្កើនការប្រមូលអត្រា ISF ដូចគ្នា ។ ថ្លៃចំណាយលើរចនាសម្ព័ន្ធនឹងមិនត្រូវបង្កើនឡើយ គឺបង្កើនសម្រាប់តែប្រតិបត្តិការ និងការថែទាំ (O&M) និងការប្រមូល ISF ប៉ុណ្ណោះ ។ យើងអាចពិចារណាពង្រីកគម្រោងដល់ទៅ ៣.៥០០ ហិកតា (ជាក់ស្តែងជាង ៤០០ ហិកតា នៅក្នុងបន្ទាយមានរាជ ៤០០ ហិកតា បន្ថែមទៀតអាចត្រូវបានគិតគូរ និង៦០០ ហិកតា នៅលើផ្នែកម្ខាងទៀតនៃប្រឡាយមេ) ។ ក្នុងអត្រា ១៥ ដុល្លារ ក្នុងមួយហិកតា FWUC អាចទូទាត់ការចំណាយរបស់ខ្លួនបាន ។

២. ការដំឡើងអត្រា ISF ខ្ពស់ជាងនេះ : ទិន្នផលស្រូវមានការកើនឡើង ហើយដំណាំដូវប្រាំងក៏មានការ អភិវឌ្ឍដូច្នេះយើងអាចរំពឹងទុកថា នឹងមានការផ្លាស់ប្តូរយ៉ាងពិតប្រាកដនៅក្នុងឥរិយាបថរបស់កសិករចំពោះទម្លាប់ធ្វើស្រែចម្ការនៅក្នុងពេលអនាគត ជាមួយនឹងការព្រមព្រៀងស្តីពីការដំឡើងអត្រា ISF ខ្ពស់ជាងនេះ ។

៣. កាត់បន្ថយរចនាសម្ព័ន្ធ FWUC និងគិតគូរអំពីការចែករំលែកបុគ្គលិកជាមួយ FWUC ផ្សេងៗទៀត (នាយកប្រតិបត្តិ ការប្រមូលផ្តុំកសិករ) ។ សេណារីយ៉ូដែលអស់ចំណាយទាប ដោយផ្អែកលើការធ្វើការរបស់គណៈកម្មាធិការដោយស្ម័គ្រចិត្ត អាចត្រូវគិតពិចារណាផងដែរ ប៉ុន្តែដោយសារភាពប្រឈមនឹងបរាជ័យដោយសារតែការតាមដាន និងការសម្របសម្រួលមិនបានល្អ គឺជាបញ្ហាសំខាន់នោះ សេណារីយ៉ូនេះនឹងមិនទទួលបានការជឿទុកចិត្តពីកសិករឡើយ ហើយក៏មិនជួយដល់ការកែលម្អទម្លាប់ដាំដុះផងដែរ ។

# ៤. ការគ្រប់គ្រងគម្រោង និងការពិចារណាសម្រាប់ការបង្កើតស្ថាប័ន

## ៤.១- ការដឹកនាំ និងការសម្របសម្រួលសម្រាប់គម្រោងធារាសាស្ត្រខ្នាតធំ




- *ការផ្តល់មូលនិធិដល់គម្រោងស្មុគស្មាញ និងការ រៀបចំការអនុវត្ត*

គម្រោងSCIRIP គឺជាគម្រោងមួយដែលត្រូវបានឧបត្ថម្ភមូលនិធិរួមគ្នាដោយម្ចាស់ជំនួយធំៗពីរគឺធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ។ ម្ចាស់ជំនួយធំៗទាំងពីរនេះបានផ្តល់មូលនិធិដល់សមាសភាពផ្សេងៗគ្នានៃគម្រោង : ADB ផ្តល់ហិរញ្ញប្បទានដល់ការគ្រោងប្លង់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ហើយ AFD ផ្តល់មូលនិធិដល់សមាសភាព "ផ្នែកទន់" នៃការកសាងសមត្ថភាពស្ថាប័នសម្រាប់ការគ្រប់គ្រងប្រកបដោយនិរន្តរភាព ។ យន្តការស្ថាប័នសម្រាប់ការអនុវត្តរួមមានប្រតិបត្តិករ និងភាគីពាក់ព័ន្ធមួយចំនួនធំ និងការបែងចែកការទទួលខុសត្រូវដ៏ស្មុគស្មាញ ។ រូបភាពទីមួយ គឺជាការព្យាយាមបង្ហាញក្នុងលក្ខណៈមួយដ៏សាមញ្ញអំពីយន្តការអនុវត្តគម្រោង ។

# ៤. ការគ្រប់គ្រងគម្រោង និងការពិចារណាសម្រាប់ការបង្កើតស្ថាប័ន

ការសម្របសម្រួលបានបង្ហាញច្បាស់ថា វាជាកត្តាដ៏ចាំបាច់ ហើយវេទិកាសម្របសម្រួលជាច្រើនត្រូវបានបង្កើតឡើង ។ ជាអកុសល កិច្ចប្រជុំសម្របសម្រួលនានាទាំងនេះពុំសម្រេចបានការបែងចែកការទទួលខុសត្រូវច្បាស់លាស់ឡើយ ហើយការដែលក្រុមសំខាន់ៗពីរ ដោយម្ខាងទទួលបន្ទុកលើការគ្រោងប្លង់ និងការសាងសង់ ហើយម្ខាងទៀតទទួលបន្ទុកលើការពិគ្រោះយោបល់ជាមួយកសិករ និងការបង្កើត និងពង្រឹង FWUC ត្រូវឆ្លើយតបទៅនឹងម្ចាស់ជំនួយផ្សេងៗគ្នាដែលមានរបៀបវារៈខុសៗគ្នា ។ បញ្ហាទាំងនេះបានបណ្តាលឱ្យមានកង្វះខាតដែលមិនអាចកែតម្រូវបាននូវការពិភាក្សាគ្នារវាងក្រុមទាំងពីរ ។ ជាមួយគ្នានេះដែរ បញ្ហានេះក៏ជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយចំពោះការពិចារណាទៅលើការចង់បានរបស់កសិករ និងឧបសគ្គនានានៅក្នុងដំណើរការនៃការរៀបចំគ្រោងប្លង់ហេដ្ឋារចនាសម្ព័ន្ធ ។

- ***ការធ្វើសេចក្តីសម្រេចចិត្តដ៏លំបាកដោយអ្នកអនុវត្តគម្រោង***

ប្រឈមមុខជាមួយនឹងចំនួនដ៏ច្រើននៃការីបច្ចេកទេសដែលមានចំណាប់អារម្មណ៍ និងទស្សនៈខុសៗគ្នា ការផ្តល់យោបល់ខុសគ្នា និងដែលពេលខ្លះផ្ទុយគ្នាផងនោះ ការិយាល័យអនុវត្ត គម្រោងរបស់ MOWRAM បានជួបប្រទះការលំបាកក្នុងការដឹកនាំគម្រោងឱ្យមានប្រសិទ្ធិភាព ។ ក្នុងករណីជាច្រើន ការធ្វើសេចក្តីសម្រេចចិត្តត្រូវបានពន្យារពេលដោយសារតែយោបល់ផ្ទុយគ្នាដែលផ្តល់ដោយការីបច្ចេកទេស និងម្ចាស់ជំនួយផ្សេងៗ ។ ពុំមានភាគីពាក់ព័ន្ធណាមួយដែលមានការយល់ដឹងទូទៅដែលចាំបាច់ទៅលើការអនុវត្តគម្រោងទាំងមូល ដើម្បីអាចផ្តល់យោបល់ប្រកបដោយប្រសិទ្ធិភាពដល់ MOWRAM អំពីជម្រើសផ្នែកបច្ចេកទេស និងជម្រើសផ្នែកស្ថាប័នឡើយ ។

# ៤. ការគ្រប់គ្រងគម្រោង និងការពិចារណាសម្រាប់ការបង្កើតស្ថាប័ន

## ៤.៣- គម្រោងសាកល្បង : ចំណាប់អារម្មណ៍ និងដែនកំណត់

ស្ទឹងជីនិត គឺជាគម្រោងទីមួយក្នុងចំណោមគម្រោងស្តារដំបូងៗ ដែលបានចាប់ផ្តើមស្របពេលជាមួយគ្នានឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ និងគ្រប់គ្រងធារាសាស្ត្រដែលមានការចូលរួមដោយ MOWRAM ។ នៅក្នុងឆ្នាំ១៩៩៩ សារាចរលេខ០១ បានដាក់ចេញនូវគោលនយោបាយបឋម និងក្របខ័ណ្ឌច្បាប់សម្រាប់ការបង្កើត FWUC ដើម្បីធានានិរន្តរភាព ប្រតិបត្តិការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ ។ ដូច្នេះស្ទឹងជីនិតត្រូវបានចាត់ទុកថាជាគម្រោងសាកល្បងមួយ ហើយលទ្ធផលនៃគម្រោងនេះ នឹងត្រូវយកទៅប្រើប្រាស់សម្រាប់ការអភិវឌ្ឍ PIMD បន្តទៀត ។

ឯកសារជំហានដំបូងបានកំណត់ការរៀបចំស្ថាប័នប្រកបដោយភាពច្នៃប្រឌិតសម្រាប់ការគ្រប់គ្រងប្រព័ន្ធ ដែលតាមរយៈការរៀបចំនេះ ស្ថាប័នរួមមួយ ដែលរួមមានសមាសភាពតំណាង PDWRAM និង FWUC នឹងត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងគម្រោង ។ ជាក់ស្តែងគណៈកម្មាធិការនេះមិនត្រូវបានបង្កើតឡើងឡើយដោយសារមូលហេតុផ្សេងៗ ។ ជាបឋម គេបានទទួលស្គាល់ថា អ្វីដែលជាអាទិភាព គឺត្រូវបង្កើត និងពង្រឹង FWUC ។ នៅក្នុងបរិយាកាសមួយដែលធារាសាស្ត្រគឺជាទម្លាប់មួយដែលទើបតែណែនាំឱ្យស្គាល់ថ្មី ការកសាងអង្គការកសិករមួយដែលមានសមត្ថភាពគ្រប់គ្រងទឹក និងថែទាំហេដ្ឋារចនាសម្ព័ន្ធ គឺជាកិច្ចការមួយដែលពោរពេញទៅដោយភាពប្រឈមរួចទៅហើយ ។ ក្រៅពីនេះការពិភាក្សាជាមួយ MOWRAM បានបង្ហាញឱ្យឃើញថា ស្ថាប័នទទួលខុសត្រូវលើការអនុវត្ត PIMD មិនបើកចំហចំពោះភាពច្នៃប្រឌិតដែលទាក់ទងនឹង FWUC ឡើយ ។ ស្ថាប័ននេះបានចាត់ទុកក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ដែលប្រកាសឱ្យប្រើប្រាស់ដោយនាយករដ្ឋមន្ត្រី គឺជាក្របខ័ណ្ឌដ៏តឹងរឹងដែលត្រូវអនុវត្តតាមនៅក្នុងការកសាងស្ថាប័ន ។ ជាចុងក្រោយ រចនាសម្ព័ន្ធ FWUC ដែលត្រូវបានបង្កើតឡើងបានអនុវត្តតាមលក្ខន្តិកៈជាបទដ្ឋាន ដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធនៃសារាចរណែនាំលេខ០១ និងត្រូវបានទទួលស្គាល់នៅក្នុងឆ្នាំ ២០០៦ ។

# ៥_ សេចក្តីសន្និដ្ឋាន

## ៥.១- ភាពចាំបាច់ក្នុងការពិចារណាទៅលើទម្លាប់របស់កសិករដែលមាននៅមុនការអនុវត្តគម្រោង និងបរិបទអេកូឡូស៊ី-កសិកម្ម/បរិបទសង្គម

បទពិសោធន៍មួយក្នុងចំណោមបទពិសោធន៍សំខាន់ៗក្នុងអំឡុងពេលនៃការអនុវត្តគម្រោង SCIRIP គឺថា ជំហានដំបូងៗរបស់គម្រោង ឧទាហរណ៍ការធ្វើអត្តសញ្ញាណកម្មគម្រោង ការសិក្សាបឋមពីមុន ការធ្វើឋានលេខា សេដ្ឋកិច្ចសង្គម និងការសិក្សាពីដី គឺជាជំហានដ៏សំខាន់ពីព្រោះ ជំហានទាំងនេះ គឺជាកត្តាគន្លឹះសម្រាប់ជោគជ័យរបស់គម្រោង ។ ការវាយតម្លៃមិនគ្រប់គ្រាន់ទៅលើឧបសគ្គផ្នែកអេកូឡូស៊ី-កសិកម្ម និងសេដ្ឋកិច្ច-សង្គមនៅដំណាក់កាលចាប់ផ្តើមបង្កើតគម្រោង បានបណ្តាលឱ្យមានផលលំបាកជាច្រើននៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ។ ការគ្រោងប្លង់ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធមិនបានល្អដែលនាំឱ្យការចំណាយលើការថែទាំមានកម្រិតខ្ពស់ខ្លាំងនៅពេលប្រៀបធៀបនឹងតម្លៃបន្ថែមដែលផ្តល់ដោយធារាសាស្ត្របានធ្វើឱ្យអន្តរាយដល់និរន្តរភាពទូទៅនៃប្រព័ន្ធធារាសាស្ត្រ ។

អន្តរាគមន៍ណាមួយនៅក្នុងតំបន់វាលទំនាបលិចទឹករបស់ប្រទេសកម្ពុជា ក៏ត្រូវគិតគូរពិចារណាដល់ជលសាស្ត្រដ៏ស្មុគស្មាញនៃសណ្ឋានដីដ៏រាបស្មើនៃវាលស្រែទំនាបក្រោមផងដែរ ។ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកដែលមានភាពបត់បែន ហើយក្នុងករណីភាគច្រើនមានភាពសមស្របជាងប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹក ។

## ៥.២- ការគាំទ្រដល់ MOWRAM នៅក្នុងការអនុវត្តគម្រោង

ការអនុវត្តគម្រោងទាំងមូល ដែលទទួលរងនូវកង្វះខាតការសម្របសម្រួលរវាងសមាសភាពផ្សេងៗគ្នា ក្រុម និងម្ចាស់ជំនួយផ្សេងៗគ្នាដែលពាក់ព័ន្ធនៅក្នុងគម្រោង ។ ការធ្វើសេចក្តីសម្រេចចិត្តត្រូវបានធ្វើឱ្យលំបាកដោយចំនួនច្រើននៃភាគីពាក់ព័ន្ធ ហើយសារផ្នែកបច្ចេកទេសត្រូវបានធ្វើឱ្យស្រពេចស្រពិលដោយសារផលប្រយោជន៍របស់ភាគីនីមួយៗ ។ នៅក្នុងការគ្រោងប្លង់គម្រោងបន្ថែមមានការផ្តល់ជាអនុសាសន៍ឱ្យផ្តល់ជំនួយដល់ការិយាល័យអនុវត្តគម្រោងរបស់ MOWRAM ។ ទីប្រឹក្សាដែលទទួលបន្ទុកជាជំនួយការអនុវត្តគម្រោងគួរត្រូវមានការយល់ដឹងទូទៅអំពីគម្រោង និងត្រូវទទួលខុសត្រូវជួយសម្រួលដល់ការត្រួតពិនិត្យ និងការសម្របសម្រួលការអនុវត្តគម្រោង ។

# ៥_ សេចក្តីសន្និដ្ឋាន

## ៥.៣- ការចែករំលែកការទទួលខុសត្រូវ

នៅក្នុងបរិបទដែលទម្លាប់កសិកម្មពឹងផ្អែកច្រើនទៅលើការធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត រដ្ឋ សហគមន៍កសិករប្រើប្រាស់ទឹក និងអាជ្ញាធរមូលដ្ឋានត្រូវតែចែករំលែកការទទួលខុសត្រូវគ្នាលើការអភិវឌ្ឍ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រសាធារណៈ ។

- ***សម្រាប់ការគ្រប់គ្រងធារាសាស្ត្រ :*** ក្រសួងទទួលខុសត្រូវលើការស្តុកទឹក និងហេដ្ឋារចនាសម្ព័ន្ធមេ ភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន (ឃុំ FWUC ...) ទទួលខុសត្រូវលើបណ្តាញចែកចាយ ។

បទពិសោធន៍សំខាន់មួយទៀតគឺថា គ្រប់ជំហានដំបូងៗទាំងអស់របស់គម្រោងចាប់ពី ការកំណត់តម្រូវការ ការចាប់កំណើតរបស់ប្រពន្ធ ការត្រួតពិនិត្យការងារដែលត្រូវគ្រប់គ្រងនៅកម្រិតមូលដ្ឋានដោយគណៈកម្មាធិការពិសេស ជាក្រុមដែលមិនមានត្រឹមតែតំណាងកសិករដែលត្រូវបានបោះឆ្នោតជ្រើសតាំង (FWUC នាពេលអនាគត) ប៉ុណ្ណោះទេ ប៉ុន្តែក៏មានទាំងសមាជិកក្រុមប្រឹក្សាឃុំ និងតំណាងមកពីប្រព័ន្ធគ្រប់គ្រងទឹកតាមបែបប្រពៃណី និង PDOWRAM ផងដែរ ។ យើងនឹងស្នើថា គម្រោងបន្ថែមនេះត្រូវបែងចែកឱ្យបានច្បាស់លាស់ (១) **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្តុកទឹកដែលអនុវត្តដោយក្រសួង** និង (២) **ការអភិវឌ្ឍបណ្តាញបន្ទាប់បន្សំ ដែលអនុវត្តក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការពិសេសដែលបង្កើតនៅក្នុងមូលដ្ឋាន** ក្រោមការឧបត្ថម្ភហិរញ្ញវត្ថុពីរដ្ឋ ឃុំ និងវិភាគទានពីកសិករ ។

នៅក្នុងសម្មតិកម្មបែបនេះ គម្រោងដែលគាំទ្រដោយម្ចាស់ជំនួយ នឹងស្ថិតនៅក្នុងជំហរល្អមួយដើម្បីផ្តល់ការគាំទ្រ (មូលនិធិ និងជំនួយបច្ចេកទេស/TA) សម្រាប់ភាគីទាំងពីរ ។

- ***ការជាប់ទាក់ទងរបស់អាជ្ញាធរមូលដ្ឋាន :*** ក្រសួង តាមរយៈ PDWRAM ទទួល O&M លើហេដ្ឋារចនាសម្ព័ន្ធមេ ហើយ FWUC ទទួល O&M លើបណ្តាញចែកចាយ ។

ការចុះបញ្ជីលក្ខន្តិកៈរបស់ FWUC ត្រូវតែចាត់ទុកជាជំហានសំខាន់នៅក្នុងដំណើរការដើម្បីធ្វើប្រតិភូកម្ម**ការគ្រប់គ្រងប្រព័ន្ធចែកចាយទឹក**ដល់កសិករ ។ ការរៀបចំឯកសារគួរតែជាកាលានុវត្តភាពមួយដើម្បីកំណត់វិសាលភាពនៃការចែករំលែកការគ្រប់គ្រង : ផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវផ្ទេរការគ្រប់គ្រងទៅឱ្យ FWUC កិច្ចការរបស់គណៈកម្មាធិការ ស.ក.ប.ទ សិទ្ធិក្នុងការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលបានព្រមព្រៀងគ្នា ។ ជាមួយនឹងលក្ខន្តិកៈបែបនេះ ដែលព្រមព្រៀង និងចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧត្តុនិយម គណៈកម្មាធិការ ស.ក.ប.ទ ត្រូវបានផ្តល់សិទ្ធិ អំណាចដើម្បីគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរង (កម្រិតទីពីរ) ។ ដើម្បីឱ្យកសិករមានការយល់ច្បាស់ ការសាងសង់បញ្ចប់ប្រព័ន្ធ ការចុះបញ្ជី លក្ខន្តិកៈ ហើយជាចុងក្រោយគឺ ការប្រគល់ត្រាជាផ្លូវការពីក្រសួងទៅឱ្យ FWUC ត្រូវតែធ្វើឡើងក្នុងពេលព្រមគ្នា ។ លក្ខន្តិកៈនេះមិនបានបង្ហាញច្បាស់លាស់ទៅតាមការស្នើឡើងយ៉ាងលម្អិតនៅក្នុងអង្គការលេខស៊ីងជីនិត និងការប្រព្រឹត្តទៅនៃអង្គការនេះឡើយ ។ ចំណុចទាំងនេះ នឹងត្រូវកំណត់ជាលក្ខណៈផ្ទៃក្នុងរបស់ ស.ក.ប.ទ តាមរយៈដំណើរការដដែលៗ និងសម្រេចជាផ្លូវការតាមរយៈបទបញ្ជាផ្ទៃក្នុងដែលត្រូវដាក់ស្នើសុំការយល់ព្រមនៅក្នុងអំឡុងពេលនៃមហាសន្និបាតលើកទីមួយ ។

# ៥. សេចក្តីសន្និដ្ឋាន

ពិធីប្រគល់ត្រាគឺជា ការចាប់ផ្តើមនៃ**រយៈពេលអន្តរកាល** ដែលក្នុងអំឡុងពេលនេះ FWUC នឹងចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធទទួលបានជំនាញតាមរយៈការធ្វើសកម្មភាពដែលជាតម្រូវការចាំបាច់សម្រាប់កិច្ចដំណើរការ និងការគ្រប់គ្រង ជាមួយនឹងការថយចុះនូវការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីក្រសួង មន្ទីរខេត្ត ឬគម្រោង ។ នៅចុងបញ្ចប់ ដោយដកស្រង់បទពិសោធន៍ពីរយៈពេលអន្តរកាលនេះ **ការផ្ទេរជាស្ថាពរនូវការគ្រប់គ្រងបណ្តាញរង** គួរត្រូវបានឯកភាពគ្នារវាងកសិករ និងរដ្ឋាភិបាល ដោយជំរុញការចូលរួមពីសំណាក់ទីភ្នាក់ងារមូលដ្ឋាននានា ដែលចាំបាច់ ។ **អនុស្សរណៈនៃការយោគយល់គ្នា** គួរត្រូវបានតាក់តែងឡើង និងចុះហត្ថលេខាដោយបញ្ចប់ដំណាក់កាលអន្តរកាល ដើម្បីបញ្ជាក់អំពីបែបបទនៃការចែករំលែកការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ភាគីទាំងអស់ ។

ការចែករំលែកនេះ ទំនងជាមានសារសំខាន់ចំពោះតម្រូវការផ្នែកថែទាំ និងការអនុវត្តថវិការបស់ក្រសួង និងកសិករ ។ ហេដ្ឋារចនាសម្ព័ន្ធដីទាមទារឱ្យមានការយកចិត្តទុកដាក់ជាប្រចាំថ្ងៃ ហើយការថែទាំពឹងផ្អែកជាចម្បងទៅលើការអនុវត្តជាប្រចាំ ។ បទពិសោធន៍នៅស្ទឹងជីនិតបង្ហាញថា FWUC ដែលមានទីតាំងនៅក្នុងមូលដ្ឋាន និងអាចប្រមូលផ្តុំកសិករបានយ៉ាងងាយ អាចគាំទ្រកិច្ចការនេះប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ ហេដ្ឋារចនាសម្ព័ន្ធបេតុងធំៗទាមទារឱ្យមានការយកចិត្តទុកដាក់ជាខួបទៀងទាត់ ហើយការថែទាំ ឬការជួសជុលអាចនាំឆ្ពោះទៅរកការងារធុនធ្ងន់ ប៉ុន្តែមានលក្ខណៈពិសេសដែលសមស្របជាមួយនឹងការអនុវត្តការគ្រប់គ្រងថវិការបស់រាជរដ្ឋាភិបាល ។

## ៥.៤- ការចូលទាក់ទងរបស់អាជ្ញាធរមូលដ្ឋាននៅក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

ក្នុងអំឡុងពេលនៃដំណើរការអនុវត្តគម្រោង SCIRIP សារសំខាន់នៃតួនាទីរបស់អាជ្ញាធរមូលដ្ឋានត្រូវបានទទួលស្គាល់ ។ បទពិសោធន៍នៅមូលដ្ឋានផ្សេងៗទៀត (ឧទាហរណ៍ គម្រោងស្តារទំនប់ការពារទឹកប្រៃព្រៃនប់) ព្រមទាំងការស្រាវជ្រាវជាច្រើនដែលបានធ្វើឡើងស្តីពី ការគ្រប់គ្រងធារាសាស្ត្រនៅក្នុងប្រទេសកម្ពុជា (TWGAW, 2006, IWMI, 2006) បាននាំទៅរកការសន្និដ្ឋានប្រហាក់ប្រហែលគ្នា ។

តួនាទីរបស់អាជ្ញាធរមូលដ្ឋានមានសារសំខាន់ជាពិសេស ទាក់ទងនឹង (១)- ការដាក់ឱ្យអនុវត្ត និងពង្រឹងវិធានការ (២)- ការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ (៣)- ការដោះស្រាយជម្លោះ ។ ជាងនេះទៅទៀត ដូចដែលបានកត់សម្គាល់នៅខាងលើ អាជ្ញាធរដែនដី ដូចជា ឃុំ អាចដើរតួនាទីកាន់តែសំខាន់មួយថែមទៀតនៅក្នុងការគ្រោងប្លង់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ជាពិសេសបណ្តាញចែកចាយទឹកស្រោចស្រព ។

ការបង្កើតគណៈកម្មាធិការ CRIC បានបង្ហាញឱ្យឃើញថា ជាការបង្កើតសាកល្បងគួរឱ្យចាប់អារម្មណ៍មួយ ដែលអនុញ្ញាតឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធិភាពពីអាជ្ញាធររដ្ឋបាល មូលដ្ឋាន ។ បទពិសោធន៍របស់ CRIC បើទោះបីជានៅតែត្រូវការការពង្រឹងបន្ថែមក្តីអាចត្រូវចាត់ទុកជាគំរូមួយដែលត្រូវយកទៅសម្រួលឱ្យស្របតាមលក្ខខណ្ឌក្នុងមូលដ្ឋាននៅក្នុងគម្រោង ផ្សេងៗទៀត ។

# ៥. សេចក្តីសន្និដ្ឋាន

## ៥.៥- ការកំណត់ឡើងវិញនូវតួនាទីរបស់រដ្ឋ

- *ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង*

ការពិតគឺថា ការបង្កើត FWUC ស្ទឹងជីនិត លើកលែងតែដំណើរការនៃការចុះបញ្ជី ត្រូវបានអនុវត្តស្ទើរតែដោយគ្មានការគាំទ្រពីក្រសួង ។ គេពុំឃើញមានមធ្យោបាយសម្រាប់ការសម្របសម្រួលណាមួយជាមួយនាយកដ្ឋាន (PIMD) របស់ក្រសួងឡើយ ។ ការគ្រោងប្លង់គម្រោងដែលចូលរួមដោយអង្គការ GRET និង CEDAC ជាប្រតិបត្តិករដែលធ្វើការងារផ្ទាល់ជាមួយសហគមន៍ បានធ្វើឱ្យពួកគេធ្វើការងារជំនួសសេវារបស់ក្រសួង ជំនួសឱ្យការកសាងសមត្ថភាពរបស់ពួកគេ ដើម្បីធ្វើការងារនេះដោយខ្លួនឯងផ្ទាល់ ។

ដូច្នេះ សំណួរគឺថា តើ MOWRAM អាចគាំទ្រការអភិវឌ្ឍ FWUC ថ្មីយ៉ាងដូចម្តេច ? ដោយមធ្យោបាយអ្វី ? បទពិសោធន៍បានបង្ហាញឱ្យឃើញថា គេត្រូវការទាំងពេលវេលា និង ជំនាញ ។

នៅស្ទឹងជីនិត មួយភាគធំនៃថវិកា និងពេលវេលា ត្រូវបានប្រមូលផ្តុំយកទៅប្រើប្រាស់ដើម្បីកសាងសមត្ថភាពរបស់ក្រុមគាំទ្រ (WUCO) : តើចាប់ពីពេលនេះទៅ ក្រសួងអាចទទួលផលប្រយោជន៍ប្រសើរបំផុតពីក្រុមជំនាញនេះយ៉ាងដូចម្តេច ?

តើតួនាទីរបស់ក្រសួងគួរត្រូវបានកម្រិតត្រឹមតែការចុះបញ្ជី និងការតាមដាន និងវាយតម្លៃឬ ? តើគេគួរផ្តល់កិច្ចសន្យាដល់ NGO ឬអង្គការជំនាញណាមួយ ( ក្រុមហ៊ុនឯកជន ឬអ្នក ផ្តល់សេវា) ដើម្បីឱ្យធ្វើកិច្ចការនោះជាមួយនឹងមូលនិធិអន្តរជាតិឬ ?

- *ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសនៅក្រោយការបញ្ចប់គម្រោង*

តម្រូវការនូវការគាំទ្ររយៈពេលវែង បង្ហាញឱ្យឃើញយ៉ាងច្បាស់នៅក្នុងគម្រោងស្ទឹងជីនិត : សម្រាប់កិច្ចការស្មុគស្មាញ តម្រូវការនូវការពន្យាសេវានានា ដើម្បីគាំទ្រកសិករនៅក្នុងការទទួលយកបច្ចេកទេសកសិករថ្មី ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការកែលម្អ ឬការពង្រីកប្រព័ន្ធស្រោចស្រព ... ។

ការឧបត្ថម្ភរយៈពេលវែងគួរត្រូវបានគិតពិចារណា ពីព្រោះភាពអាចសម្រេចបានក្នុងការគ្រប់គ្រងទឹក គឺពឹងផ្អែកទៅលើការកែលម្អទម្លាប់ធ្វើស្រែចម្ការ ដែលអាចសម្រេចបាននៅពេលដែលនិរន្តរភាពនៃការគ្រប់គ្រងទឹកដែលពាក់ព័ន្ធ ត្រូវបានបង្ហាញឱ្យកសិករឃើញច្បាស់ និងនៅពេលដែលកាលានុវត្តភាពទីផ្សារត្រូវបានបង្កើតឡើង ។ វាជាដំណើរការដ៏វែង ហើយរយៈពេល ៥ឆ្នាំពិតជាមិនគ្រប់គ្រាន់ ជាពិសេសនៅក្នុងតំបន់ដីអន់ខ្លាំងដែលមានខ្យាច់ ។

តើរដ្ឋាភិបាលអាចផ្តល់ការឧបត្ថម្ភធនផ្នែកធារាសាស្ត្រកសិកម្មតាមរយៈជំនួយរយៈពេលវែងដល់ FWUC បានដែរឬទេ ដើម្បីកសាង និងធ្វើឱ្យប្រព័ន្ធធារាសាស្ត្រដែលគ្រប់គ្រង បានល្អនោះមាននិរន្តរភាព ?

# ៥. សេចក្តីសន្និដ្ឋាន

## ៥.៦- ការលេចឡើងនូវសេវាគាំទ្រជំនាញដល់ FWUC

ដោយពិចារណាម្យ៉ាងទៀតទៅលើភាពចាំបាច់នៃការមានការគាំទ្រដល់ FWUC រយៈពេលវែងឱ្យហួសពីថិរវេលានៃគម្រោង និងម្យ៉ាងទៀត ពិចារណាទៅលើសមត្ថភាពដែលមាន កម្រិតរបស់ MOWRAM និង PDWRAM ដើម្បីថែរក្សាក្រុមគាំទ្រឱ្យមានលទ្ធភាពផ្តល់ការគាំទ្រប្រចាំថ្ងៃនោះ គេពិនិត្យឃើញថា មានស្ថាប័នទទេមួយដែលត្រូវបានធ្វើឱ្យខូចខាតដោយ ក្រុមគាំទ្រគម្រោង នៅក្នុងអំឡុពេលនៃការអនុវត្តគម្រោង SCIRIP ។ ប៉ុន្តែនៅក្រោយការបញ្ចប់គម្រោងជាស្ថាពរហើយនោះ FWUC ស៊ីងជីនិតទំនងជាទាមទារឱ្យមានការគាំទ្រ ផ្នែកបច្ចេកទេសបន្ថែមទៀតសម្រាប់កិច្ចការជំនាញៗ និងដោយផ្អែកលើមូលដ្ឋានមិនសូវទៀងទាត់មួយ ។

ក្រៅពីនេះ FWUC ផ្សេងទៀតនៅកម្រិតខេត្ត និងកម្រិតជាតិ ក៏នឹងត្រូវការជាចាំបាច់នូវសេវាគាំទ្របែបនេះផងដែរ ។ ដំណោះស្រាយមួយដែលត្រូវបានគិតគូរដើម្បីដោះស្រាយ បញ្ហានេះ គឺការបង្កើតឱ្យមានមជ្ឈមណ្ឌលសេវាគាំទ្រជំនាញនៅកម្រិតមូលដ្ឋាន ។ "មជ្ឈមណ្ឌលសេវាកម្ម FWUC" នេះ នឹងផ្តល់សេវាកម្មផ្នែកប្រឹក្សាយោបល់បច្ចេកទេសទៅតាមតម្រូវការ ដល់ FWUC និងពង្រឹងសមត្ថភាពរបស់ ស.ក.ប.ទ នៅក្នុងអំឡុងនៃរយៈពេលបង្កើត និងរយៈពេលអន្តរកាល ។

ពុំមានការប្រឆាំងគ្នាឡើយរវាងម្ខាងជារដ្ឋ ដែលទទួលខុសត្រូវលើការអភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធស្តុកទឹក និងប្រឡាយមេធំៗ និងតាមដាន និងវាយតម្លៃ FWUC និងម្ខាងទៀតជាតួអង្គនៅក្នុងមូលដ្ឋាន (អាជ្ញាធរដែនដី FWUC មជ្ឈមណ្ឌលសេវាកម្ម FWUC) ដែលនឹងចូលរួមចំណែកក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងបណ្តាញចែកចាយទឹកសម្រាប់ស្រោចស្រព ។ ផ្ទុយ ទៅវិញ សំណើបែបនេះកំពុងទាញយកអត្ថប្រយោជន៍ជាក់លាក់ពីភាគីពាក់ព័ន្ធនីមួយៗ ដែលត្រូវបានកំណត់នៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង SCIRIP ។

ប៉ុន្តែអ្វីដែលសំខាន់ជាពិសេសនោះ គឺត្រូវកត់សម្គាល់ថា នៅក្នុងករណីណាមួយក៏ដោយ និរន្តរភាពនៃការអភិវឌ្ឍ កិច្ចប្រតិបត្តិការ និងការថែទាំប្រព័ន្ធធារាសាស្ត្រនៅក្នុងប្រទេសកម្ពុជា ត្រូវតែពឹងផ្អែកលើភាពជាដៃគូរវាងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន និងទាមទារឱ្យមានការគាំទ្រតាមក្រោយដើម្បីកសាងសមត្ថភាពមូលដ្ឋាន ក្នុងគោលបំណងកែលម្អទម្លាប់ធ្វើកសិកម្ម និងការគ្រប់គ្រងទឹកនាពេលបច្ចុប្បន្ន ។ កិច្ចអន្តរាគមន៍របស់ម្ចាស់ជំនួយនៅក្នុងវិស័យនេះ គឺត្រូវតម្រង់ទៅលើការលើកទឹកចិត្ត និងការគាំទ្រឱ្យមានកិច្ចសហប្រតិបត្តិការបែបនេះ ។